១. ទិន្នន័យដែលប្រមូល ចងក្រង និងវិភាគ មកពីប្រភពទីភ្នាក់ងារជាតិមុខរបរ និងការងារ៖

- ទិន្នន័យរដ្ឋបាលស្តីពីការចុះឈ្មោះ អ្នកស្វែងរកការងារធ្វើ និយោជក និងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល
- ទិន្នន័យរដ្ឋបាលស្តីពីព័ត៌មានជ្រើសរើសបុគ្គលិក និងឱកាសការងារ
- ទិន្នន័យអង្កេតស្តីពីតម្រូវការជ្រើសរើសបុគ្គលិកក្នុងពេលអនាគត តាមប្រភេទនៃអាជីព ជំនាញ ការអប់រំ វិស័យ និងតំបន់ភូមិសាស្ត្រ ដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាល សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ក្រុមហ៊ុន សហគ្រាសឯកជន និងសាធារណៈទាំងអស់ និងនិយោជកផ្សេងៗទៀត
- ទិន្នន័យអង្កេតស្តីពីការលើស និងកង្វះជំនាញក្នុងពេលបច្ចុប្បន្ន និងពេលអនាគត
- លទ្ធផលការសិក្សាស្រាវជ្រាវអំពីទីផ្សារការងារ និង
- ព័ត៌មានទីផ្សារការងារដទៃទៀត។

២. ទិន្នន័យដែលប្រមូល ចងក្រង និងវិភាគ មកពីប្រភពវិទ្យាស្ថានជាតិស្ថិតិ និងអង្គភាពស្ថិតិដែលបានចាត់តាំងនៃក្រសួង ស្ថាប័នរាជរដ្ឋាភិបាល និងប្រភពផ្សេងៗទៀត៖

- ទិន្នន័យស្តីពីការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម និងការព្យាករណ៍ក្នុងពេលអនាគត តាមប្រភេទនៃមុខរបរ ជំនាញ និងវិស័យ
- ទិន្នន័យស្តីពីប្រាក់ឈ្នួល និងអត្រាគ្មានការងារធ្វើ ក្នុងពេលបច្ចុប្បន្ន និងការព្យាករណ៍ក្នុងពេលអនាគត
- ព័ត៌មានស្តីពីការអប់រំបណ្តុះបណ្តាល និងតម្រូវការការអប់រំបណ្តុះបណ្តាលក្នុងពេលបច្ចុប្បន្ន និងការព្យាករណ៍ក្នុងពេលអនាគត
- ព័ត៌មានស្តីពីការណែនាំអំពីអាជីព និងទស្សនវិស័យមុខរបរ
- ព័ត៌មានស្តីពីផែនការ និងគម្រោងអភិវឌ្ឍន៍និងវិនិយោគថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល និងផ្នែកឯកជន ដែលមានទំនាក់ទំនងទៅនឹងទីផ្សារការងារ
- ព័ត៌មានស្តីពីគោលនយោបាយ ច្បាប់ កម្មវិធី និងវិធានការទីផ្សារការងារ និង
- ព័ត៌មាន ទិន្នន័យ និងឯកសារផ្សេងៗដែលពាក់ព័ន្ធទៅនឹងព័ត៌មានទីផ្សារការងារ។

**មាត្រា ៥.-**

គ្រប់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល មានកាតព្វកិច្ចរដ្ឋបាលក្នុងការផ្តល់ឯកសារ ព័ត៌មាន និងទិន្នន័យតាមទម្រង់ដែលបានចងក្រងរួច ឬតាមទម្រង់កម្រងសំណួរ ឬទម្រង់ស្ថិតិរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងផ្តល់ការសហការយ៉ាងជិតស្និទ្ធ ជូនទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បីបំពេញការកិច្ចប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដូចមានចែងក្នុងមាត្រា ៤ ខាងលើនេះ ។

**មាត្រា ៦.-**

សមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិនានា ដោយត្រូវផ្តល់ឯកសារ ព័ត៌មាន និងទិន្នន័យតាមទម្រង់ដែលបានចងក្រងរួច ឬតាមទម្រង់កម្រងសំណួរ ឬទម្រង់ស្ថិតិរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងរបាយការណ៍រៀងរាល់ ៣(បី)ខែម្តង អំពីតម្រូវការកម្លាំងពលកម្ម ជំនាញ មុខរបរ និងអត្រាប្រែប្រួលនៃចំនួនបុគ្គលិក ផ្ញើមកកាន់ទីភ្នាក់ងារជាតិមុខរបរ និងការងារឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីឱ្យទីភ្នាក់ងារជាតិនេះបំពេញភារកិច្ចប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ។

**មាត្រា ៧.-**

បណ្តាក្រុមហ៊ុន សហគ្រាសឯកជននិងសាធារណៈទាំងអស់ និងនិយោជកផ្សេងៗទៀត ត្រូវគោរពច្បាប់ និងបទប្បញ្ញត្តិនានាដោយត្រូវផ្តល់ឯកសារ ព័ត៌មាន និងទិន្នន័យតាមទម្រង់ដែលបានចងក្រងរួច ឬតាមទម្រង់កម្រងសំណួរ ឬទម្រង់ស្ថិតិរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងរបាយការណ៍រៀងរាល់ ៣(បី)ខែម្តង អំពីតម្រូវការកម្លាំងពលកម្ម ជំនាញ មុខរបរ និងអត្រាប្រែប្រួលនៃចំនួនបុគ្គលិកផ្ញើមកកាន់ទីភ្នាក់ងារជាតិមុខរបរ និងការងារឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីឱ្យទីភ្នាក់ងារជាតិនេះ បំពេញភារកិច្ចប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ។

**មាត្រា ៨.-**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវទទួលខុសត្រូវក្នុងការតម្រូវឱ្យគ្រប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ បញ្ជាក់អំពីតម្រូវការកម្លាំងពលកម្មតាមឆ្នាំនីមួយៗ នៃគម្រោងវិនិយោគតាមវិស័យដោយបែងចែកតាមប្រភេទ នៃមុខរបរ ជំនាញ និងការសិក្សាអប់រំ ហើយត្រូវផ្ញើនូវរាល់ព័ត៌មានទាំងនេះមកកាន់ទីភ្នាក់ងារជាតិ មុខរបរ និងការងារឱ្យបានទៀងទាត់ និងទាន់ពេលវេលា ដើម្បីធ្វើការប្រមូល វិភាគ និងចងក្រង។

## ជំពូកទី៣
## សិទ្ធិ និងភារកិច្ច

**មាត្រា ៩.-**

អនុលោមទៅតាមអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ទីភ្នាក់ងារជាតិមុខរបរ និងការងារ មិនត្រូវបោះពុម្ព និងផ្សព្វផ្សាយនូវលទ្ធផល ឬសម្រង់សង្ខេបព័ត៌មានទីផ្សារការងារដែលបានចងក្រង និងវិភាគ តាមរបៀបដែលអាចនាំឱ្យស្គាល់អត្តសញ្ញាណរបស់បុគ្គល ឬអង្គភាពណា

មួយឡើយ លើកលែងតែមានការយល់ព្រមពីបុគ្គល ឬអង្គភាពនោះ ឬដូចមានចែងក្នុងមាត្រា ២៥ នៃ អនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។

**មាត្រា ១០.-**

មន្ត្រីដែលបម្រើការងារ នៅទីភ្នាក់ងារជាតិមុខរបរ និងការងារ ដែលទទួលបន្ទុកក្នុងការប្រមូល ចងក្រង និងវិភាគព័ត៌មានទីផ្សារការងារ ដោយអនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ ត្រូវជានានូវ៖

- ភាពស្មោះត្រង់
- រក្សាការសម្ងាត់នូវរាល់ព័ត៌មានបុគ្គល ដែលទទួលបានពីអ្នកឆ្លើយ និង
- ព័ត៌មានដែលប្រមូលបាន ត្រូវប្រើប្រាស់សម្រាប់តែគោលដៅ ក្នុងការបង្កើតប្រព័ន្ធព័ត៌មានទីផ្សារការងារប៉ុណ្ណោះ។

**មាត្រា ១១.-**

ស្របតាមមាត្រា ២៦ នៃអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ មន្ត្រីទីភ្នាក់ងារជាតិមុខរបរ និងការងារដែលត្រូវបានប្រគល់សិទ្ធិឱ្យចុះប្រតិបត្តិការប្រមូលព័ត៌មានទីផ្សារការងារ ត្រូវបង្ហាញលិខិតបញ្ជាបេសកកម្ម អត្តសញ្ញាណប័ណ្ណរបស់ខ្លួន និងដោយមានការអនុញ្ញាតពីម្ចាស់កម្មសិទ្ធិ ឬអ្នកស្នាក់នៅ អាចចេញ ចូលក្នុងបរិវេណលំនៅឋាន ឬទីកន្លែងស្នាក់នៅនិងទីកន្លែងផ្សេងៗទៀត ដើម្បី ៖

- ផ្តល់កម្រងសំណួរ ឬទម្រង់ស្ថិតិឱ្យបុគ្គលបំពេញ
- ប្រមូលកម្រងសំណួរ ឬទម្រង់ស្ថិតិដែលបុគ្គលបានបំពេញរួចហើយ និង
- ធ្វើសម្ភាសន៍ និងបំពេញការងារផ្សេងៗទៀត សម្រាប់គោលបំណងប្រមូល និងចងក្រងប្រព័ន្ធព័ត៌មានទីផ្សារការងារ។

ក្នុងកិច្ចដំណើរការប្រមូល និងចងក្រងព័ត៌មានទីផ្សារការងារ ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារមានសិទ្ធិ និងកាតព្វកិច្ចដូចមានចែងក្នុងមាត្រា ២៧ នៃអនុក្រឹត្យស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១១៧ .អនក្រ. បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ សរសេរកាត់ថា **ម.ជ.ព.** ដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលផ្នែកបច្ចេកទេសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថិតនៅក្រោមអាណាព្យាបាលផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២.-**

**ម.ជ.ព.** ជានីតិបុគ្គល និងមានស្វ័យភាពហិរញ្ញវត្ថុ។

**ម.ជ.ព.** មានទីស្នាក់ការកណ្តាលនៅមជ្ឈមណ្ឌលជាតិស្តារលទ្ធភាពពលកម្មជនពិការគៀនឃ្លាំង ស្ថិតនៅភូមិគៀនឃ្លាំង សង្កាត់ជ្រោយចង្វា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ការផ្លាស់ប្តូរអាសយដ្ឋាននៅពេលអនាគតជាសមត្ថកិច្ចរបស់ **ម.ជ.ព.**។

**មាត្រា៣.-**

**ម.ជ.ព.** មានភារកិច្ចជាអាទិ៍ ដូចតទៅ ៖

- ផ្តល់សេវាស្តារលទ្ធភាពពលកម្ម ជូនជនពិការ
- គ្រប់គ្រងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ជូនជនពិការ
- ផ្តល់មូលនិធិ សម្រាប់ការអនុវត្តគម្រោងកម្មវិធីផ្សេងៗ ដែលជួយដល់ជនពិការ និងគាំទ្រដល់ស្ថាប័ន គ្រឹះស្ថាននានា ដែលផ្តល់សេវាកម្មដល់ជនពិការ ដូចជា ផ្នែកសុខាភិបាល ស្តារលទ្ធភាពពលកម្ម អប់រំ បណ្តុះបណ្តាលបច្ចេកទេស វិជ្ជាជីវៈ និងការរកការងារធ្វើ
- លើកកម្ពស់ និងបង្កើនសុខុមាលភាពជនពិការ
- ធ្វើសមាហរណកម្មជនពិការទៅក្នុងសហគមន៍
- គ្រប់គ្រងថវិកាដែលទទួលបានពីការឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ប្រភពហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាលនានា និងទទួលអំណោយសប្បុរសធម៌ពីសប្បុរសជន និងផលចំណេញពីការវិនិយោគ និងអាជីវកម្មស្របច្បាប់
- ប្រមូលភាគទាន ប្រាក់ពិន័យអន្តរការណ៍ និងប្រាក់ពិន័យផ្សេងៗទៀត ពីប្រធានស្ថាប័នរដ្ឋ និងនីតិបុគ្គល ដែលមិនអាចបំពេញតាមកាតព្វកិច្ច ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- បំផុសលើកទឹកចិត្តពលរដ្ឋ សប្បុរសជនផ្នែកឯកជន និងអង្គការសង្គមឧបត្ថម្ភដល់ជនពិការ

- រៀបចំគោលនយោបាយផ្គត់ផ្គង់ និងឧបត្ថម្ភដល់ជនពិការ
- រៀបចំហិរញ្ញប្បទានវិភាគទានសប្បុរសធម៌ សម្រាប់ជនពិការ
- រៀបចំឲ្យមានមូលនិធិ សម្រាប់សេវាកម្មផ្សេងៗ ជាប្រយោជន៍ដល់ជនពិការ
- ចាត់ចែង និងគ្រប់គ្រងការវិនិយោគមូលនិធិនៃ **ម.ជ.ព.**
- ស្រាវជ្រាវបច្ចេកទេស និងបណ្តុះបណ្តាលធនធានមនុស្សក្នុងការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ
- ធ្វើសហប្រតិបត្តិការនានា ក្រោមការណែនាំពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី ២
## ការដឹកនាំ និងការគ្រប់គ្រងរបស់ ម.ជ.ព.
## ផ្នែកទី ១
## ក្រុមប្រឹក្សាភិបាលរបស់ ម.ជ.ព.

**មាត្រា៤.-**

**ម.ជ.ព.** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលដែលមានសិទ្ធិទូលំទូលាយ ដើម្បីចាត់ចែងការងារក្នុងក្របខណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ព.**។

**មាត្រា៥.-**

៥.១. ក្រុមប្រឹក្សាភិបាលមានសមាជិក ៩ (ប្រាំបួន) រូប ដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងអង្គការជនពិការ ដែលជាជនពិការ | សមាជិក |
| - លេខាធិការក្រុមប្រឹក្សាសកម្មភាពជនពិការ | សមាជិក |
| - ប្រធានរដ្ឋបាលសិទ្ធិជនពិការ | សមាជិក |
| - ឥស្សរជនដែលមានចំណេះដឹង និងបទពិសោធខាងវិស័យសង្គមកិច្ច | សមាជិក |
| - នាយក **ម.ជ.ព.** | សមាជិក |
| - តំណាងបុគ្គលិកនៃ **ម.ជ.ព.** | សមាជិក។ |

៥.២.តំណាងបុគ្គលិកនៃ**ម.ជ.ព.** ត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក**ម.ជ.ព.** សម្រាប់អាណត្តិនីមួយៗ។

៥.៣.ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យ សម្រាប់អាណត្តិ ៣ (បី) ឆ្នាំ និងអាចបន្តបានទៀត តាមសំណើរបស់ក្រសួង ឬស្ថាប័ន ដែលសមាជិក នោះជាតំណាង។

៥.៤.អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលាដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ឬស្ថាប័នដែលសមាជិកនោះជាតំណាង។

**មាត្រា៦._**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្ម ធ្លាប់បានបម្រើការងារយ៉ាង តិច ៥ (ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានបទពិសោធគ្រប់គ្រាន់ មានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងមានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលបានទទួលទណ្ឌកម្មពីបទមជ្ឈិម ឬបទឧក្រិដ្ឋឡើយ។

**មាត្រា៧._**

៧.១.ប្រធានក្រុមប្រឹក្សាភិបាលមានភារកិច្ចកោះប្រជុំនិងកំណត់របៀបវារៈនៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

៧.២.ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធលើវិស័យវិទ្យាសាស្ត្រសេដ្ឋកិច្ច សង្គមកិច្ច និងតំណាងដៃគូអភិវឌ្ឍឲ្យចូលរួមអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាលបាន។ ឥស្សរជនទាំងនោះមានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ។

**មាត្រា៨._**

ក្រុមប្រឹក្សាភិបាលនៃ **ម.ជ.ា.** មានបេសកកម្មដឹកនាំ តម្រង់ទិស និងត្រួតពិនិត្យដំណើរការរបស់ **ម.ជ.ា.**។ ក្នុងក្របខណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

- ពិនិត្យ និងសម្រេចលើគម្រោងផែនការអភិវឌ្ឍនៃ **ម.ជ.ា.** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និងសម្រេចលើគម្រោងផែនការសកម្មភាពនៃ **ម.ជ.ា.**
- ពិនិត្យ និងសម្រេចលើចំណូល និងចំណាយប្រចាំឆ្នាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ា.**
- ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពីការងារគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងការបែងចែកភារកិច្ចជាទូទៅដល់គ្រប់ការិយាល័យ និងអង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍតាមការចាំបាច់របស់ **ម.ជ.ា.**
- កំណត់បែបបទនៃការជ្រើសរើស ការដំឡើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក **ម.ជ.ា.** ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ ឬបទបញ្ជាផ្ទៃក្នុងដែលអនុវត្តចំពោះមន្ត្រីមុខងារសាធារណៈ
- សម្រេចលើក្របខណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសម្រាប់ **ម.ជ.ា.**
- សម្រេចលើកិច្ចសន្យាស្តីពីលទ្ធកម្មសាធារណៈ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃលទ្ធកម្មសាធារណៈ

- កែសម្រួលបទបញ្ជាផ្ទៃក្នុងនៃ **ម.ជ.ឆ.** ដោយមានការយល់ព្រមពីប្រធានស្ថាប័ន ឬ ក្រសួងអាណាព្យាបាលទាំងពីរ
- វាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅ កំណត់ដោយ **ម.ជ.ឆ.** ហើយកំណត់វិធានការកែតម្រូវដើម្បីអនុវត្ត។

**មាត្រា៩.-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។

**មាត្រា១០.-**

១០.១.ក្រុមប្រឹក្សាភិបាលនៃ **ម.ជ.ឆ.** ត្រូវធ្វើការប្រជុំយ៉ាងតិច ៣ (បី) ខែម្តង តាមគំនិតផ្តួចផ្តើម និង ការអញ្ជើញរបស់ប្រធាន ឬតាមការស្នើរបស់សមាជិកចំនួន ២/៣ (ពីរភាគបី) ឡើងទៅ ឬតាមការស្នើសុំរបស់ នាយក **ម.ជ.ឆ.**។ ក្នុងករណីមានធុរៈ ប្រធានត្រូវផ្ទេរសិទ្ធិជូនសមាជិកណាម្នាក់ក្នុងចំណោមសមាជិកក្រុម ប្រឹក្សាភិបាល ដើម្បីដឹកនាំការប្រជុំ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ១ (មួយ) រូប ដែល មិនមែនជាសមាជិកនៃក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ។

របៀបវារៈព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ ក្រសួង ស្ថាប័នពាក់ព័ន្ធដូចមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ។

១០.២.ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានចំនួនសមាជិកលើសពី ៥០ (ហាសិប) ភាគរយនៃចំនួនសមាជិកទាំងអស់។ សមាជិកអវត្តមានគ្មានសិទ្ធិបញ្ជូនតំណាងឲ្យមកប្រជុំជំនួសខ្លួន បានឡើយ។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀតយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឲ្យមានកូរ៉ុមគ្រប់ចំនួនឡើយ ហើយ ត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញលើកមុន។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័តដោយសំឡេង ភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានអង្គប្រជុំមានឧត្តមានុភាព។

១០.៣.សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ ការរបស់ **ម.ជ.ឆ.** និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ។ កំណត់ហេតុនេះ ត្រូវបង្ហាញអត្ថន័យនៃការពិភាក្សាឲ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើ ជូនក្រសួងពាក់ព័ន្ធយ៉ាងយូរ ១០ (ដប់) ថ្ងៃក្រោយពេលប្រជុំ។

១០.៤.**ម.ជ.ឆ.** ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោម៖

- កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់ **ម.ជ.ព.**
- គម្រោងថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។

១០.៥.ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួលក្នុងរយៈពេលមិនហួសពី ១៥ (ដប់ប្រាំ) ថ្ងៃ។

## ផ្នែកទី ២
## អង្គភាពប្រតិបត្តិរបស់ ម.ជ.ព.

**មាត្រា១១.-**

**ម.ជ.ព.** ត្រូវគ្រប់គ្រងដោយនាយកមួយរូបដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នាយកមានតួនាទីជានាយកប្រតិបត្តិ។

**មាត្រា១២.-**

១២.១.នាយក **ម.ជ.ព.** មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល។

នាយក **ម.ជ.ព.** មានភារកិច្ច ៖

- រៀបចំការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍ និងថវិកាប្រចាំឆ្នាំរបស់ **ម.ជ.ព.** ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំ ត្រួតពិនិត្យគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **ម.ជ.ព.** ក្នុងការកម្រិតក្របខណ្ឌចំនួនបុគ្គលិកដែលកំណត់ដោយ ក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងអស់របស់ **ម.ជ.ព.** ដែលក្រុមប្រឹក្សាភិបាលកំណត់តាមការបែងចែកសិទ្ធិអំណាច និងតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឲ្យដំណើរការនូវគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាភិបាល។

១២.២. នាយក **ម.ជ.ព.** ជាតំណាងរបស់មូលនិធិជនពិការ ក្នុងការទាក់ទងជាមួយតតិយជន។

១២.៣.នាយក **ម.ជ.ព.** ត្រូវស្នើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សុំតែងតាំងនាយករង មួយរូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។ នាយក និងនាយករងត្រូវមានចំណេះដឹងលើផ្នែកគ្រប់គ្រង។

## ជំពូកទី ៣
## បុគ្គលិករបស់ ម.ជ.ព.

**មាត្រា១៣.-**

១៣.១.បុគ្គលិកអចិន្ត្រៃយ៍របស់ **ម.ជ.ព.** មានមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬមកពីក្រសួងស្ថាប័នរដ្ឋដទៃទៀត។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកក្របខណ្ឌ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ ដែលកំណត់ដោយមុខងារសាធារណៈ ពីអង្គភាពដើមរបស់ខ្លួន។

១៣.២. **ម.ជ.ព.** អាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ជំនួយការ និងបុគ្គលិកអណ្តែត ។ បុគ្គលិកទាំងនេះ ត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ស្តីពីការងារ។

១៣.៣.បុគ្គលិក **ម.ជ.ព.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាស្តីពីការគ្រប់គ្រងបុគ្គលិកដែលសម្រេចដោយក្រុមប្រឹក្សាភិបាល។ ចំពោះមន្ត្រីនៃមុខងារសាធារណៈ បទបញ្ជានេះមិនត្រូវផ្ទុយពីបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងអត្ថបទពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការឡើយ។

ក្រុមប្រឹក្សាភិបាលត្រូវកំណត់ប្រាក់កម្រៃ លើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ដូចមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង។

## ជំពូកទី ៤
## រចនាសម្ព័ន្ធរបស់ ម.ជ.ព.

**មាត្រា១៤.-**

រចនាសម្ព័ន្ធរបស់ **ម.ជ.ព.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃ **ម.ជ.ព.**។

## ជំពូកទី ៥
## ទ្រព្យសម្បត្តិរបស់ ម.ជ.ព.

**មាត្រា១៥.-**

១៥.១.**ម.ជ.ព.**ទទួលដើមទុនដំបូងពីរដ្ឋនូវអចលនទ្រព្យដែលមានបញ្ជាក់ក្នុងបញ្ជីសារពើភណ្ឌចុងក្រោយដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ។

១៥.២. **ម.ជ.ព.** អាចទិញ ប្តូរ ឬលក់ចលនទ្រព្យ អចលនទ្រព្យចាំបាច់សម្រាប់ដំណើរការមូលនិធិបានដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន។

## ផ្នែកទី ៦
## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់ ម.ជ.ព.

**មាត្រា១៦.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យរបស់**ម.ជ.ព.** ត្រូវប្រព្រឹត្តស្របតាមគោលការណ៍នៃគណនេយ្យសាធារណៈដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ។

**មាត្រា១៧.-**

១៧.១.នាយក **ម.ជ.ព.** ជាអាណាប័កដើមខ្សែរបស់មូលនិធិជនពិការហើយត្រូវមានភារកិច្ចៈ

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ។

១៧.២.អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរជ្ជទេយ្យចំណូល ឬបុរេប្រទានបានដោយមានការព្រមព្រៀងពីគណនេយ្យករ **ម.ជ.ព.**។

**មាត្រា១៨.-**

១៨.១.ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ **ម.ជ.ព.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ។ គណនេយ្យករត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ។ គណនេយ្យករនេះត្រូវទទួលខុសត្រូវចំពោះមុខនាយក **ម.ជ.ព.**និងត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកពិគ្រោះយោបល់តែឥតមានសំឡេងឆ្នោតឡើយ។

១៨.២. គណនេយ្យករមានភារកិច្ច ៖

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- ថែរក្សា និងចាត់ចែងប្រើប្រាស់មូលនិធិ និងធនធានរបស់ **ម.ជ.ព.**
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ។

១៨.៣. គណនេយ្យករអាចផ្ទេរសិទ្ធិខ្លះទៅឲ្យអាជ្ញានុការីរបស់ខ្លួន។

**មាត្រា១៩.-**

១៩.១. ប្រភពធនធានរបស់ **ម.ជ.ព.** រួមមាន ៖

- ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ **ម.ជ.ព.** នៅពេលផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធនដែលមានចែងក្នុងថវិកាជាតិ
- អំណោយ ជំនួយ និងអច្ច័យទានដែល **ម.ជ.ព.** បានទទួល
- ប្រាក់ខ្ចីដោយផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឲ្យ **ម.ជ.ព.**

- ផលការងារ និងកម្រៃនៃការផ្តល់សេវាផ្សេងៗ ដោយ ម.ជ.ព.
- កម្រៃនៃទ្រព្យរបស់ ម.ជ.ព. និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលត្រូវបានទទួលអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលត្រូវបានប្រគល់ឲ្យ ម.ជ.ព.
- ប្រាក់ចំណូលពីវិភាគទានដែលប្រមូលបានពីហិបប្រាក់វិភាគទានសប្បុរសធម៌សម្រាប់ជនពិការ
- ប្រាក់ភាគទាន ប្រាក់ពិន័យអន្តរការណ៍ និងប្រាក់ពិន័យផ្សេងៗទៀត ដូចមានចែងក្នុងមាត្រា ៣៧ និងមាត្រា ៥៤ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ។

១៩.២.ចំណូលចំណាយជាប្រចាំព្រមទាំងមូលធនរបស់ ម.ជ.ព. ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់មូលនិធិ។ ក្រុមប្រឹក្សាភិបាលរបស់ ម.ជ.ព. ត្រូវកំណត់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងនឹងទម្រង់បែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកាត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

១៩.៣.ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ ម.ជ.ព. ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ។ ថវិកាត្រូវតែធ្វើឲ្យមានលំនឹងរវាងចំណូល និងចំណាយ។

១៩.៤.អនុលោមតាមមាត្រា ១៣ ខាងលើនេះ ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗ នៃមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈដែលមកបម្រើការងារក្នុង ម.ជ.ព. ជាបន្ទុកនៃថវិការដ្ឋ។

១៩.៥.ប្រាក់ឧបត្ថម្ភរបស់រដ្ឋដែលបានគ្រោងទុកក្នុងថវិកាជាតិ ដើម្បីផ្តល់ឲ្យ ម.ជ.ព. ត្រូវសំដៅជាពិសេសលើចំណាយថ្លៃទឹក និងថ្លៃអគ្គិសនី។

១៩.៦.សោហ៊ុយវិភាគ និងសោហ៊ុយដំណើរការសម្រាប់ស្រាវជ្រាវវិភាគចាំបាច់ផ្សេងៗ ត្រូវចែងក្នុងកិច្ចសន្យារវាងរដ្ឋ និង ម.ជ.ព. ដែលមានបញ្ជាក់ចំណែកដែលភាគីម្ខាងៗត្រូវរ៉ាប់រង។

**មាត្រា២០.-**

២០.១. ការងារគណនេយ្យរបស់ ម.ជ.ព. រួមមាន ៖

-គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគដែលចែងអំពីប្រតិបត្តិការថវិការតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យអសង្ហារិម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់។

គណនេយ្យរបស់ ម.ជ.ព. ត្រូវ ៖

- ស្របតាមវិធានការដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យរបស់ ម.ជ.ព. ដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាភិបាល។

ប្លង់គណនេយ្យនេះត្រូវបានយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២០.២. របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ម.ជ.ព. ត្រូវរៀបចំដោយគណនេយ្យករ និងអាណាប័កដើមខ្សែដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី) ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ។

**មាត្រា២១.-**

មូលនិធិរបស់ ម.ជ.ព. គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយនៅអគ្គនាយកដ្ឋានរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ផ្នែកទី ៧
## របបសារពើពន្ធរបស់ ម.ជ.ព.

**មាត្រា២២.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលមានចែងដោយច្បាប់ ម.ជ.ព. ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធ។

## ផ្នែកទី ៨
## លទ្ធកម្មរបស់ ម.ជ.ព.

**មាត្រា២៣.-**

ការសម្រេច ការអនុវត្ត និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ ម.ជ.ព. ត្រូវគ្រប់គ្រងតាមច្បាប់ និងបទបញ្ញាទាំងឡាយជាធរមាន ដែលមានការពាក់ព័ន្ធនឹងកិច្ចការនេះ។

# ជំពូកទី ៣
# អាណាព្យាបាល
## ផ្នែកទី ១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា២៤.-**

២៤.១. ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពេលប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ នាយក ម.ជ.ព. ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវកម្មវិធីអភិវឌ្ឍ និងគម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃទទួលឯកសារដើម្បីរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរយៈពេល ២ (ពីរ) ខែ ចាប់ពីថ្ងៃទទួលឯកសារដែលបានបញ្ជូនដោយនាយក ម.ជ.ព. ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

២៤.២.លិខិតយល់ព្រមចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬតំណាងត្រូវផ្ញើជូនទៅនាយក **ម.ជ.ព.** ដោយមានចម្លងជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នាយក **ម.ជ.ព.** ត្រូវបញ្ជូនព័ត៌មាននេះ ទៅឲ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាទទួលបានការឯកភាព។ ប្រសិនបើរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍ ឬគម្រោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ដើម្បីពិភាក្សា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ។

កម្មវិធីអភិវឌ្ឍនៃ **ម.ជ.ព.** និងថវិកាចំណាយជាមូលធនមិនអាចឲ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

ថវិកាចំណាយជាប្រចាំអាចដាក់ឲ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះនៅពេលដែលមានការជំទាស់ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា២៥.-**

២៥.១.រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចមានយោបល់ជំទាស់លើឯកសារដែលបានបញ្ជូនមកដូចមានចែងក្នុងមាត្រា ១០ ចំណុច ១០.៤ នៃអនុក្រឹត្យនេះ មានកំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរយៈពេល ១ (មួយ) ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ។

២៥.២.នាយក **ម.ជ.ព.** ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាលអំពីខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រុមប្រឹក្សាភិបាល ត្រូវពិភាក្សាឲ្យបានឆាប់បំផុតលើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរិះរកមធ្យោបាយដោះស្រាយការជំទាស់នេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសម្រេចពុំយកជាការបាននូវការជំទាស់ទាំងនោះ សេចក្តីសម្រេច របស់ក្រុមប្រឹក្សាភិបាល ត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជម្រាបជាបន្ទាន់ភ្លាមនូវដំណឹងអំពីបញ្ហានេះជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា២៦.-**

២៦.១. រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចលុប ឬផ្អាកទុកសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក **ម.ជ.ព.** ក្នុងករណីដែលសេចក្តីសម្រេចនោះ ៖

- ផ្ទុយនឹងគោលដៅរបស់ **ម.ជ.ព.**
- ផ្ទុយនឹងច្បាប់ និងបទបញ្ញា

- ធ្វើឡើងដោយអាជ្ញាធរមួយដែលពុំមានសិទ្ធិសម្រេច ឬធ្វើឡើងដោយការប្រជុំពុំស្រប ច្បាប់របស់ក្រុមប្រឹក្សាភិបាល។

២៦.២. ការលុបចោល ឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្តីសម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក **ម.ជ.ព.** ហើយនាយក **ម.ជ.ព.** ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត។

**មាត្រា២៧.-**

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចចាត់ឲ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យការងាររបស់ **ម.ជ.ព.** ក្នុងករណីដែលយល់ថា ជាការចាំបាច់ស្របតាមលក្ខខណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ផ្នែកទី ២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា២៨.-**

២៨.១. ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក **ម.ជ.ព.** ត្រូវផ្ញើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានរយៈពេល ១ (មួយ) ខែ ចាប់ពីថ្ងៃទទួលឯកសារដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ២ (ពីរ) ខែ ចាប់ពីថ្ងៃទទួលឯកសារ ដែលបញ្ជូនមកដោយនាយក **ម.ជ.ព.** ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ។

២៨.២.លិខិតយល់ព្រមចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាងត្រូវផ្ញើទៅនាយក **ម.ជ.ព.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ នាយក **ម.ជ.ព.** ត្រូវបញ្ជូនព័ត៌មាននេះទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើរបាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឲ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ។ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ។

**មាត្រា២៩.-**

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក **ម.ជ.ឆ.** ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួមមាន ៖

- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានា ឬលិខិតស្រដៀងគ្នានេះ
- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនទ្រព្យ។

សេចក្តីសម្រេចនេះ ត្រូវអនុលោមតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៣០.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ១ (មួយ) រូប ប្រចាំ**ម.ជ.ឆ.**។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើ **ម.ជ.ឆ.** ស្របតាមអនុក្រឹត្យលេខ ៨១អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥។

**មាត្រា៣១.-**

៣១.១.ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែនៃ **ម.ជ.ឆ.** ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣១.២.ការគ្រប់គ្រងរបស់គណនេយ្យករត្រូវស្ថិត នៅក្រោមការត្រួតពិនិត្យរបស់គណនេយ្យករកណ្តាលនៃអគ្គនាយកដ្ឋានរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣១.៣.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬការត្រួតពិនិត្យលើ **ម.ជ.ឆ.** នៅពេលយល់ថាជាការចាំបាច់ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា៣២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

តារាងឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជនពិការ

## ទីតាំង និងផ្ទៃក្រឡាដីរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទារាជធានី ខេត្ត

| ល.រ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទា | ទីតាំង | | | | ទំហំផ្ទៃក្រឡាដី |
|---|---|---|---|---|---|---|
| | | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង/ខណ្ឌ | រាជធានី/ខេត្ត | |
| ១ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រៃវែង | ភូមិបារាយលិច | សង្កាត់បារាយណ៍ | ក្រុងព្រៃវែង | ខេត្តព្រៃវែង | ១៣ ៤៦៣ ម៉ែត្រក្រឡា |
| ២ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តតាកែវ | ភូមិ III | សង្កាត់រកាក្នុង | ក្រុងដូនកែវ | ខេត្តតាកែវ | ៤ ២៨២ ម៉ែត្រក្រឡា |
| ៣ | មជ្ឈមណ្ឌលស្តារស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តបាត់ដំបង | ចំការសំរោង | សង្កាត់ចំការសំរោង | ក្រុងបាត់ដំបង | ខេត្តបាត់ដំបង | ១៣ ៣៤៤ ម៉ែត្រក្រឡា |
| ៤ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ចាម | ភូមិទី ៧ | សង្កាត់កំពង់ចាម | ក្រុងកំពង់ចាម | ខេត្តកំពង់ចាម | ២ ៩១៨ ម៉ែត្រក្រឡា |
| ៥ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ឆ្នាំង | កណ្តាល | សង្កាត់កំពង់ឆ្នាំង | ក្រុងកំពង់ឆ្នាំង | ខេត្តកំពង់ឆ្នាំង | ១ ១២៨.៩២ ម៉ែត្រក្រឡា |
| ៦ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តកំពង់ធំ | ភូមិទី៧ | សង្កាត់កំពង់ធំ | ក្រុងស្ទឹងសែន | ខេត្តកំពង់ធំ | ៥៧៤ ម៉ែត្រក្រឡា |
| ៧ | មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រះវិហារ | គោកបេង | សង្កាត់កំពង់ប្រណាក | ក្រុងព្រះវិហារ | ខេត្តព្រះវិហារ | ១២ ៦០០ ម៉ែត្រក្រឡា |
| ៨ | មជ្ឈមណ្ឌលព្យាបាលរបួសខួរឆ្អឹងខ្នង | ចំការសំរោង | សង្កាត់ចំការសំរោង | ក្រុងបាត់ដំបង | ខេត្តបាត់ដំបង | ១០ ៣៥៤ ម៉ែត្រក្រឡា |
| ៩ | មជ្ឈមណ្ឌលជាតិស្តារលទ្ធភាពពលកម្មជនពិការគៀនឃ្លាំង | គៀនឃ្លាំង | សង្កាត់ជ្រោយចង្វារ | ខណ្ឌឫស្សីកែវ | ក្រសួងស.អ.យ | ២២ ៦[illegible]២ ម៉ែត្រក្រឡា |
| ១០ | សាលាបណ្តុះបណ្តាលអ្នកបច្ចេកទេសផលិតអវៈយវៈសិប្បនិម្មិត និងរណបកម្ពុជា ភ្នំពេញ | គោកចំបក់ | សង្កាត់ចោមចៅ | ខណ្ឌដង្កោ | ក្រសួងស.អ.យ | ៤ ៦[illegible] ម៉ែត្រក្រឡា |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៦៣ . អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ សេនា ជូនលោកស្រីវេជ្ជបណ្ឌិត ប្លូវីយេ ដេជេន ហ្វាប៊ីយ៉ែន (Dr.PLOUVIER DEJENS Fabienne ) ដែលមានស្នាដៃល្អក្នុងការបំពេញបេសកកម្ម នៅព្រះរាជាណាចក្រកម្ពុជា ចាប់តាំពីថ្ងៃទី០១ ខែមីនា ឆ្នាំ ២០០៧ រហូតដល់ឆ្នាំ ២០១០ នៅមន្ទីរពេទ្យកាល់ម៉ែត និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ក្នុងនាមជាសាស្ត្រាចារ្យជួយបណ្តុះបណ្តាលថ្នាក់ជំនាញឯកទេសផ្នែកប្រពោធនកម្មនិងសង្គ្រោះបន្ទាន់ ទទួលបានលទ្ធផលល្អប្រសើរ ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៦៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន ឧត្តមសេនីយ៍ត្រី **ហ៊ុន ម៉ាណែត** អត្តលេខ ០៣៣៨៨៣ ជា មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស និងជានាយរងសេនាធិការចំរុះ អគ្គបញ្ជាការដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយ សហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១ ៶**

ត្រូវបានបំពាក់មេដាយ **សហមេត្រី ថ្នាក់ធិបឌិន្ទ** ជូនដល់លោក Adam McNeil លេខាទី១ នៃស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ដែលបានជួយឧបត្ថម្ភគាំទ្រក្នុងការផ្លាស់ប្តូរព័ត៌មានសំខាន់ៗជាប្រចាំ និងជួយដល់ការងារបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២ ៶**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩១៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនអស់លោក លោកស្រី ជានាយនគរបាលជាតិ ចំនួន ១១ រូប ដែលមានស្នាដៃក្នុងការបំពេញភារកិច្ចជូនជាតិបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម

| | | |
|---|---|---|
| ១-លោកវរសេនីយ៍ទោ ខួន ច័ន្ទឫទ្ធី | ០៦៤៣២ | នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ២-លោកវរសេនីយ៍ទោ សំ ស៊ីផា | ០១២១១ | នាយការិយាល័យ នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ៣-លោកវរសេនីយ៍ទោ ឆាត់ ឃិន | ០១២០០ | នាយរងការិយាល័យ នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ៤-លោកវរសេនីយ៍ទោ នួន សុខា | ០១២១២ | នាយរងការិយាល័យ នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ៥-លោកវរសេនីយ៍ទោ ខុន ដល្លា | ០១២១៤ | នាយរងការិយាល័យ នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ៦-លោកវរសេនីយ៍ត្រី លាង សេងគ្រី | ០៥០៦៥ | នាយរងការិយាល័យ នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ៧-លោកវរសេនីយ៍ត្រី ម៉ិន ឃុនណាង | ០៦៣៦៩ | នាយរងការិយាល័យ នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ៨-លោកវរសេនីយ៍ត្រី ចាប មុយហុង | ៦៤២៦៧ | មន្ត្រី នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |
| ៩-លោកអនុសេនីយ៍ឯក ដោត ឧត្តី | ៣០៣២០ | នាយផ្នែក នៃនាយកដ្ឋានប្រឆាំងភេរវកម្ម |

១០-លោកអនុសេនីយ៍ឯក សុខ ហួន ៣៧៧៥០ នាយផ្នែក នៃនាយកដ្ឋានប្រឆាំងភេរវកម្ម

១១-លោកស្រីអនុសេនីយ៍ឯក ម៉ែន ធីតាមុនី ៣០៣០៥ នាយផ្នែក នៃនាយកដ្ឋានប្រឆាំងភេរវកម្ម

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៦៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ អភិបាល នៃគណៈអភិបាលខេត្តកណ្តាល

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានយកអស់ កម្លាំងកាយ-ចិត្ត ព្រមទាំងចំណាយធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា គមនាគមន៍ សេដ្ឋកិច្ច សង្គម អភិវឌ្ឍន៍ជនបទ ពិសេសវិស័យអប់រំ សិក្សាធិការ នៅតាមបណ្តាឃុំនានា ក្នុងស្រុកស្អាង ខេត្តកណ្តាល ដូចមានរាយខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:**

១- លោក ពៅគីម ចំនួរ័ត្ន
២- លោក ឈៀង គុណា
៣- លោក វង សុក្រសិរី
៤- លោក ព្រាប សុន្ទារ៉ា

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

- លោក ខេង ច័ន្ថា

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៦៨.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ចំនួន ៣១ គ្រឿង ជូននាយទាហាន និងសាស្ត្រាចារ្យវេជ្ជបណ្ឌិតស៊ីវិល ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយបង្ហាត់បង្រៀន ដល់សិស្សនិស្សិត នៃវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាល សម្រេចទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ÷

**ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ហេង** | **តៃគ្រី** | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល |
| ២- លោក | **រ័ត្ន** | **សុខា** | ប្រធាននាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំយុវជន និងកីឡា |
| ៣- លោកវេជ្ជបណ្ឌិត | **ឈាង** | **រ៉ា** | នាយក មន្ទីរពេទ្យកាល់ម៉ែត្រ |
| ៤- លោកសាស្ត្រាចារ្យ | **ឃួន** | **វិចិត្រ** | មន្ទីរពេទ្យកាល់ម៉ែត្រ |
| ៥- លោកវេជ្ជបណ្ឌិត | **សុខ** | **សុគន្ធ** | ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ |
| ៦- លោកវេជ្ជបណ្ឌិត | **លឹម** | **ម៉េងស៊ាង** | មន្ទីរពេទ្យព្រះអង្គឌួង |
| ៧- វរសេនីយ៍ឯក | **គង្គ** | **ម៉ិនធឿន** | អត្តលេខ ០០១៣៥៤ នាយការិយាល័យពតិមានវិទ្យា អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ |

៨- វរសេនីយ៍ឯក **ប្រាក់ សុវណ្ណា** អត្តលេខ ០០១៣១៨ លេខា ឯកឧត្តម **យុន ខុង** អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

**ខ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

១-លោកវេជ្ជបណ្ឌិត **អ៊ុំ សុខុម** មជ្ឈមណ្ឌលជាតិប្រយុទ្ធជម្ងឺកាមរោគ

២-លោកវេជ្ជបណ្ឌិត **ទី គៀនហ៊ី** មន្ទីរពេទ្យគន្ធបុប្ផា

៣-លោកវេជ្ជបណ្ឌិត **ដា ឌីវ៉ាដា** មន្ទីរពេទ្យកុមារជាតិ

៤-លោកវេជ្ជបណ្ឌិត **គីម អាង** មន្ទីរពេទ្យកុមារជាតិ

៥-លោកវេជ្ជបណ្ឌិត **ឌីង ដា** មន្ទីរពេទ្យកុមារជាតិ

៦-លោកវេជ្ជបណ្ឌិត **គុង ហុង** មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត

៧-លោកវេជ្ជបណ្ឌិត **សែម មន្ទីរ** មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត

៨-លោកសាស្ត្រាចារ្យ **សាន់ ចាន់សឿន** ក្រសួងសុខាភិបាល

៩-លោកវេជ្ជបណ្ឌិត **ថៃ ហ្វា** មន្ទីរពេទ្យព្រះកុសុមៈ

១០-លោកស្រីឱសថការីឧត្តម **គាត គួង** ប្រធាននាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស ក្រសួងសុខាភិបាល

១១-លោកស្រីវេជ្ជបណ្ឌិត **ទូច សុខនាង** អនុប្រធាននាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស ក្រសួងសុខាភិបាល

១២-លោកវេជ្ជបណ្ឌិត **តាំ សំសុង** អនុប្រធាននាយកដ្ឋានអភិវឌ្ឍធនធានមនុស្ស ក្រសួងសុខាភិបាល

១៣- លោកស្រី **ម៉ក់ ណារាង** អនុប្រធាននាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំយុវជន និងកីឡា

**គ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

១- លោកស្រីវេជ្ជបណ្ឌិត **ឌីម ខន្តី** មន្ទីរពេទ្យព្រះកេតុមាលា

២- លោកវេជ្ជបណ្ឌិត **ហាឌ្យ សេរីវុធ** មន្ទីរពេទ្យព្រះកេតុមាលា

៣- លោកវេជ្ជបណ្ឌិត **ណាស៊ី សារ៉ុត** មន្ទីរពេទ្យព្រះកេតុមាលា

៤- លោកវេជ្ជបណ្ឌិត **រិត ចាន់** មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត

៥- លោកវេជ្ជបណ្ឌិត **ចក់ ធីតា** មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត

៦- លោកវេជ្ជបណ្ឌិត **កើត ឈុនលី** មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត

៧- លោកវេជ្ជបណ្ឌិត **អាំង អេងសុភាព** មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត

៨- លោកវេជ្ជបណ្ឌិត **លឹម តាំង** មន្ទីរពេទ្យព្រះកុសុមៈ

៩- លោកវេជ្ជបណ្ឌិត **ខាត់ ឌុនតារាផល** មន្ទីរពេទ្យព្រះកុសុមៈ

១០-លោកវេជ្ជបណ្ឌិត **ថា ពុទ្ធរតនៈ** មន្ទីរពេទ្យព្រះកុសុមៈ

**មាត្រា២** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៦៩ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន សមាគម និងក្រុមទូរទស្សន៍ ដែលបានផ្តល់ថវិកាក្នុងការជួយកសាងអគារសិក្សា នៅក្នុងខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

១-ក្រុមទូរទស្សន៍ NIPPON TELEVISION NETWORK CORPORATION បានផ្តល់ថវិកាចំនួន ៣២.៣៤៤.៥៦ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ០១ ខ្នង មាន០៣បន្ទប់ បង្គន់អនាម័យ ០៤ បន្ទប់ និងអាងទឹក០១ ជូនដល់សាលាបឋមសិក្សា បុស្សធំ ស្ថិតនៅឃុំខ្នារពោធិ ស្រុកសូទ្រនិគម ។

២-សមាគម GENMAI KOSO Co,.Ltd បានផ្តល់ថវិកាចំនួន ៣២.៣៤៤.៥៦ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ០១ខ្នង មាន០៣បន្ទប់ បង្គន់អនាម័យ ០៤បន្ទប់ និងអាងទឹក ០១ ជូនដល់សាលាបឋមសិក្សាគ្រៀលពង ស្ថិតនៅឃុំពពេល ស្រុកសូទ្រនិគម ។

៣-លោកស្រី FUJIKO OHWAKI , OHWAKI Co., Ltd បានផ្តល់ថវិកាចំនួន ២៣.៧៧១.៧០ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០៤បន្ទប់ និងអណ្តូងទឹក ០១ ជូនដល់សាលាបឋមសិក្សាក្បាលដំរី ស្ថិតនៅឃុំពង្រលើ ស្រុកជីក្រែង ។

៤-លោក HARUO NAKATANI , NAKAHYO Co., Ltd បានផ្តល់ថវិកាចំនួន ២៣.៧៧១.៧០ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០៤បន្ទប់ និងអណ្តូងទឹក ០១ ជូនដល់សាលាបឋមសិក្សាក្បាលដំរី ស្ថិតនៅឃុំពង្រលើ ស្រុកជីក្រែង ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ [illegible] ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៧៨.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនលោកវរសេនីយ៍ឯក **សេង អៀ** អត្តលេខ ០១៤១០៤ ជា នាយការិយាល័យអនុព័ន្ធយោធា និងជាទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជា ប្រចាំក្រុងយ៉ាងហ្គូន សហភាពមីយ៉ាន់ម៉ា ជំនួសលោក វរសេនីយ៍ឯក **ជៀប រំដោះ** ដែលត្រូវចប់អាណត្តិ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៤៧..សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដំណើរការអនុវត្តការកាត់ឃុំចំនួន ២០ នៃខេត្តកណ្តាលមកបញ្ចូលក្នុងរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដំណើរការអនុវត្តការកាត់ឃុំចំនួន ២០ នៃខេត្តកណ្តាលមកបញ្ចូលក្នុងរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម ៖

១-ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន
២-ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
៣-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៤-រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
៥-រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
៦-រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
៧-រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
៨-រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
៩-តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក
១០-ឯកឧត្តម **លេខ ទី** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក
១១-ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ សមាជិក
១២-ឯកឧត្តម **ឈុន ស៊ីរុន** អភិបាលខេត្តកណ្តាល សមាជិក
១៣-ឯកឧត្តម **ម៉ៅ ច័ន្ទតារា** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
១៤-ឯកឧត្តម **ឌុច សុន** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក
១៥-ឯកឧត្តម **អែម ម៉ុនថុល** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក
១៦-ឯកឧត្តម **សុខ ហេង** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក
១៧-ឯកឧត្តម **ចែម ទុន្តរិការ** ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក
១៨-លោក **យិន ម៉ាលីណា** ប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សមាជិក
១៩-ប្រធានមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនៃរាជធានីភ្នំពេញ និងខេត្តកណ្តាល ដែលចាត់តាំងដោយអភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្តកណ្តាល សមាជិក

**ប្រការ ២.-**

គណៈកម្មការអន្តរក្រសួង មានភារកិច្ចដូចខាងក្រោម ៖

- សិក្សា និងប្រមូលព័ត៌មានទាំងឡាយដែលពាក់ព័ន្ធនឹងកាត់ឃុំចំនួន ២០ នៃខេត្តកណ្តាល មកបញ្ចូលក្នុងរាជធានីភ្នំពេញ
- វាយតម្លៃអំពីផលប៉ះពាល់ផ្សេងៗដែលអាចកើតមានឡើង និងចាត់វិធានការដោះស្រាយឱ្យបានសមស្រប
- សម្របសម្រួលដោះស្រាយបញ្ហាផ្សេងៗដែលទាក់ទងនឹងការកាត់ឃុំខាងលើនេះ
- សិក្សាលទ្ធភាព និងរៀបចំបែបបទក្នុងការបង្កើតខណ្ឌថ្មី ឬកែសម្រួលព្រំប្រទល់រដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ
- រៀបចំបែបបទ និងឯកសារពាក់ព័ន្ធនឹងការផ្ទេរប្រជាពលរដ្ឋ ទ្រព្យសម្បត្តិ ហេដ្ឋារចនាសម្ព័ន្ធ មន្ត្រីបុគ្គលិក និងឯកសារលិខិតស្នាមនានាពីខេត្តកណ្តាល មករាជធានីភ្នំពេញ បន្ទាប់ពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល ។

**ប្រការ ៣.-**

ក្នុងការអនុវត្តការងារ ប្រធានគណៈកម្មការអន្តរក្រសួងត្រូវសុំយោបល់ដឹកនាំផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

អនុប្រធាន និងសមាជិកគណៈកម្មការអន្តរក្រសួង ត្រូវបំពេញការងារក្រោមការចាត់ចែងរបស់ប្រធាន ។

**ប្រការ ៤.-**

ក្នុងករណីចាំបាច់ គណៈកម្មការអន្តរក្រសួងអាចបង្កើតក្រុមការងារជាជំនួយការ ។

**ប្រការ ៥.-**

រាជធានីភ្នំពេញត្រូវបង្កើតឱ្យមានក្រុមការងាររបស់ខ្លួន ដែលកំណត់ដោយសេចក្តីសម្រេចរបស់អភិបាលរាជធានីភ្នំពេញ ។

ខេត្តកណ្តាលត្រូវបង្កើតឱ្យមានក្រុមការងាររបស់ខ្លួន ដែលកំណត់ដោយសេចក្តីសម្រេចរបស់អភិបាលខេត្តកណ្តាល ។

**ប្រការ ៦.-**

ក្រុមការងាររបស់រាជធានីភ្នំពេញ និងក្រុមការងាររបស់ខេត្តកណ្តាល ត្រូវសហការជាមួយគណៈកម្មការអន្តរក្រសួង និងក្រុមការងាររបស់គណៈកម្មការអន្តរក្រសួង ឱ្យអនុវត្តសម្រេចបាននូវភារកិច្ចរបស់ខ្លួន ។

**ប្រការ ៧.-**

គណៈកម្មការអន្តរក្រសួងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃក្នុងការចាត់ចែងការងាររបស់ខ្លួន ។

**ប្រការ ៨.-**

គណៈកម្មការអន្តរក្រសួងត្រូវបញ្ចប់កិច្ចការរបស់ខ្លួន បន្ទាប់ពីបានបំពេញភារកិច្ចរបស់ខ្លួនក្នុងការកាត់ឃុំចំនួន ២០ នៃខេត្តកណ្តាលមកបញ្ចូលក្នុងរាជធានីភ្នំពេញ ចប់សព្វគ្រប់ជាស្ថាពរ ។

**ប្រការ ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការមុខងារសាធារណៈ អភិបាលរាជធានីភ្នំពេញ អភិបាលខេត្តកណ្តាល និងឯកឧត្តម អស់លោកដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...២៤២...សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១០

# ប្រកាស
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន
- យោងតាមសំណូមពរការងារចាំបាច់

## សម្រេច

**ប្រការ ១.-**

បង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ហៅកាត់ថា លេខាធិការដ្ឋាន គជសដ (National Cross-Border Transport Facilitation Committee – NCTFC Secretariat) ។ លេខាធិការដ្ឋាននេះមានទីតាំងនៅអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់បម្រើការងាររបស់ខ្លួន ស្របតាមបញ្ញត្តិមាត្រា ១ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែនដូចយោងខាងលើ ។

**ប្រការ ២.-**

លេខាធិការដ្ឋាន គជសដ មានសមាសភាពចូលរួមពីមន្ត្រីរាជការគយនិងរដ្ឋាករ ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- លោក សៀង ឈុនទ្រី | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | ប្រធាន |
| ២- បណ្ឌិត គុណ ញឹម | អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា | អនុប្រធាន |
| ៣-បណ្ឌិត ប៉ែន សំអាត | ប្រធាននាយកដ្ឋានកិច្ចការច្បាប់ សវនកម្ម និងទំនាក់ទំនងសាធារណៈ | អនុប្រធាន |
| ៤- លោក នួន ច័ន្ទរិទ្ធ | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | អនុប្រធាន |
| ៥- លោក អ៊ុយ សារិន | ប្រធាននាយកដ្ឋានរបបគយ | អនុប្រធាន |
| ៦- លោក ប៊ូរ ប៊ុនណាក់ | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៧- បណ្ឌិត សង់ស៊ីណាវិទ្យ | ជំនួយការនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ៨- លោក សុខ សុវិទ្យា | អនុប្រធានទទួលបន្ទុករួមការិយាល័យបច្ចេកទេសគយ | សមាជិក |
| ៩- លោក យិន សុឌីណា | អនុប្រធានទទួលបន្ទុករួមការិយាល័យកិច្ចការអន្តរជាតិ | សមាជិក |
| ១០-លោក សែម ម៉េង | អនុប្រធានការិយាល័យគ្រប់គ្រងហានិភ័យ និងសវនកម្មគយនិងរដ្ឋាករ | លេខាអចិន្ត្រៃយ៍ |
| ១១- លោក ហ៊ិល ប៊ុនថា | អនុប្រធានការិយាល័យគោលនយោបាយ និងគ្រប់គ្រងតំបន់រួចពន្ធ | សមាជិក |
| ១២- លោក សុខ ទ្រី | អនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ១៣- លោក យុត វីរៈខឹម | ជំនួយការការិយាល័យត្រួតពិនិត្យ | សមាជិក |
| ១៤- លោក ជា សំណាង | ភ្នាក់ងារគយនិងរដ្ឋាករការិយាល័យបច្ចេកទេសគយ | សមាជិក |
| ១៥- លោក លន ចិត្រា | ភ្នាក់ងារគយនិងរដ្ឋាករការិយាល័យបច្ចេកទេសគយ | សមាជិក |

**ប្រការ ៣.-**

លេខាធិការដ្ឋាន គជសដ មានភារកិច្ច ដូចខាងក្រោម ៖

- ជាចំណុចទាក់ទងសម្រាប់សម្របសម្រួលការងារនានារបស់ គជសដ ជាមួយស្ថាប័ន និងបុគ្គលពាក់ព័ន្ធ ឲ្យដំណើរការប្រកបដោយប្រសិទ្ធភាព តាមតួនាទី ភារកិច្ច និងសិទ្ធិរបស់ គជសដ តាមបញ្ញត្តិមាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន។
- ជាសេនាធិការរបស់ គជសដ លើការងារស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃនូវនីតិវិធី និងបទប្បញ្ញត្តិច្បាប់ជាធរមាន ពាក់ព័ន្ធនឹងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែននូវទំនិញ មធ្យោបាយដឹកជញ្ជូន និងអ្នកដំណើរ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន និងការអនុវត្តល្អជាអន្តរជាតិ ។ ក្នុងករណីចាំបាច់ ត្រូវរៀបចំនូវសេចក្តីព្រាងបទប្បញ្ញត្តិដែលមានប្រសិទ្ធភាពជាង ហើយដាក់ជូន គជសដ ដើម្បីពិនិត្យលទ្ធភាពសុំការសម្រេចពីរាជរដ្ឋាភិបាល ។
- ចាត់ចែងផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់បុគ្គលពាក់ព័ន្ធ ជាពិសេសសហគមន៍ធុរកិច្ចឲ្យមានការយល់ដឹងច្បាស់លាស់អំពីនីតិវិធី និងបែបបទនៃការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។
- ទទួល ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំ គជសដ នូវរាល់សំណូមពរ ឬការតវ៉ានានារបស់បុគ្គលពាក់ព័ន្ធនឹងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន តាមបទប្បញ្ញត្តិច្បាប់ជាធរមាន និងការអនុវត្តល្អជាអន្តរជាតិ ។

៥

- ចូលរួមរៀបចំកិច្ចប្រជុំនានារបស់ គជសដ និងចូលរួមកសាងកញ្ចប់ថវិកាមួយដោយឡែក ក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានានិរន្តរភាពនៃកិច្ចប្រតិបត្តិការ និងមុខងារនៃ គជសដ ។
- ធ្វើរបាយការណ៍ជាប្រចាំពីវឌ្ឍនភាពនានា នៃកិច្ចដំណើរការរបស់ គជសដ និងរបាយការណ៍ផ្សេងទៀតតាមការកំណត់របស់ប្រធាន គជសដ។
- បំពេញភារកិច្ចផ្សេងទៀត តាមការកំណត់របស់ប្រធាន គជសដ ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា "ដើម្បីសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៧៦៦ ឧ.រ.ថ.ក១.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ ២១៥/០៩ គ.វ.ក ចុះថ្ងៃទី០៦.០២.២០០៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន លី ស៊ីង នីតធីង ហ្វេកធើរី លីមីធីត ចុះថ្ងៃទី២៥.០៦.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន លី ស៊ីង នីតធីង ហ្វេកធើរី លីមីធីត តំណាងដោយ លោក HUANG DIANZHAO សញ្ជាតិចិន អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G39310345 ចុះថ្ងៃទី៣១.០៣.២០១០ មានអាសយដ្ឋានបច្ចុប្បន្ន៖ No.2-4, St., Dong Shi, Xi Xian Guan Li Chi, Xi Tian Chen, Hui Lai Xian, Guang Dong, China ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| សម្លៀកបំពាក់ (កាត់ដេរ និងចាក់) | ៣២២០ |

-ផ្លាកឈ្មោះរោងចក្រ ៖ *" លី ស៊ីង នីតធីង ហ្វេកធើរី លីមីធីត (LIXING KNITTING FACTORY LIMITED)"*

-ទីតាំងរោងចក្រ ៖ *" ផ្ទះលេខ៨០៥A ភូមិមានជ័យ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ"*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។ /ល

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់ សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោម តាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌ ទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។
-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យ បានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែល ប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** ប្រកាសលេខ ១២០ ឧរថ.កឧ.ប្រក និង វិញ្ញាបនបត្រលេខ ០០៥ ឧរថ.កឧ.បរ ចុះថ្ងៃ ទី២៧.០១.២០០៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើត រោងចក្រ កាត់ដេរ និង ចាក់សម្លៀកបំពាក់ របស់ក្រុមហ៊ុន លី ស៊ីង នីតធីង ហ្វេកធើរី លីមីធីត ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ១៦:** ប្រកាសនេះមានអនុភាពតតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៤០ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហ្គែល ឡូជីស្ទីក អិលធីឌី**
**GAL LOGISTICS LTD.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៤៣៦៩/០៩P ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩
មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ម៉ាល់ តន្ត្រា** ប្រធានក្រុមប្រឹក្សាភិបាល
កញ្ញា **ម៉ាល់ស័ក្ត សំណាង** "តតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៤៤ ផ្លូវលេខ ៤៣២ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -បញ្ចេញ ...ទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទនីប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

**ហួ-សារ៉ាន់**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៤២ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឌី រីសសស៍ ឌីវេឡុបមេន**

**THE RESOURCES DEVELOPMENT Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ១៤៣៨២/០៩ P** ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **ចាន់ សុវណ្ណចុល** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **លឹម ឃី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.000.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២១០ ផ្លូវលេខ ៦៣ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូននិងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

រដ្ឋលេខាធិការ

ហ៊ូ-សារ៉ាន់

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ ០០៤៤ ពណ.ចបព**

**ភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១០**

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អ៊ឹង ជីន ឆាយ អ៊ិមផត អិចផត**

**UNG JIN CHHAY IMPORT EXPORT Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ១៤៣៨៦/០៩P** ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩

មានទម្រង់ទ្រព្យជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **អ៊ឹង ស៊ីថា** ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី **ឌឿ ខារឡេន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២៨៤-២៨៦ មហាវិថីម៉ៅសេទុង សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម :ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ទិញ លក់រថយន្តគ្រប់ប្រភេទ -នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទុកផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និង ចែកចាយទំនិញ

-សេវាយកកិច្ចការដើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

**ធេសរដ្ឋមន្ត្រី**

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

**ហ៊ូ-សារ៉ាន់**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

កសន - ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០០៤៧ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ជំរាបមក**

លោកប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន CONNOR INTERNATIONAL LIMITED
អាសយដ្ឋាន : 6/F , The Harbourfront Off. Tower2 18-22 Tak Fung St. Hung Hom HK.

**កម្មវត្ថុ** : ករណីសុំបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន **ខននើរ អ៊ិនធើណេសិនណល លីមីធីត** Representative Office of CONNOR INTERNATIONAL LIMITED ប្រចាំព្រះរាជាណាចក្រកម្ពុជា

**យោង** : -សំណើរបស់ក្រុមហ៊ុន ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩
-លិខិតតែងតាំងរបស់ក្រុមហ៊ុនដើម ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩

តាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជំរាបលោកថា : ក្រសួងពាណិជ្ជកម្មទទួលចុះបញ្ជីនូវការបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន **ខននើរ អ៊ិនធើណេសិនណល លីមីធីត** Representative Office of CONNOR INTERNATIONAL LIMITED (ចុះបញ្ជីនៅហុងកុង) ប្រចាំព្រះរាជាណាចក្រកម្ពុជាដែលមាន លោកស្រី SNG BEE LIAN AUDREY កាន់លិខិតឆ្លងដែនលេខ S 1556318 D ចុះថ្ងៃទី 22-02-2003 ជានាយកការិយាល័យតំណាង និងមានទីស្នាក់ការតាំងនៅលេខ ១៧៨ ផ្លូវលេខ ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

រាល់ដំណាច់ឆ្នាំនីមួយៗ នាយកការិយាល័យពាណិជ្ជកម្មក្រុមហ៊ុនមានកាតព្វកិច្ច មកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ការិយាល័យតំណាងនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

រាល់សកម្មភាពរបស់ការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុននេះ ត្រូវគោរពប្រតិបត្តិទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អាស្រ័យហេតុនេះ សូមលោកស្រីជ្រាបនិងអនុវត្តតាមការសមស្រប ។

**ទេសរដ្ឋមន្ត្រី**
**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**ហូ_សារ៉ាន់**

**ចម្លងជូន** :
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា -ក្រសួងមហាផ្ទៃ
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-សាលារាជធានីភ្នំពេញ
-មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
ឯ.ប -ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០០៥២ **ពណ.ចបព**

**ភ្នំពេញថ្ងៃទី** ០៥ **ខែ** មករា **ឆ្នាំ** ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

សាខាក្រុមហ៊ុនបរទេសមួយត្រូវបានចុះបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

| | | |
|---|---|---|
| ១- | នាមករណ៍របស់ក្រុមហ៊ុនដើម | : **HEMISPHERES FOUNDATION PTE LTD.** |
| | នាមករណ៍របស់សាខា | : **សាខាក្រុមហ៊ុន ហេមីស្វែរ ហ្វោនដេសិន ភីធីអ៊ី អិលធីឌី (ខេមបូឌា)** <br> **Branch of HEMISPHERES FOUNDATION PTE LTD. ( CAMBODIA )** |
| | អត្តលេខចុះបញ្ជីពាណិជ្ជកម្ម | : Co. **៥៦៨/០៩** B ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ |
| ២- | នាយកសាខាក្រុមហ៊ុន | : លោកស្រី **ANG SWEE ANN** |
| ៣- | ទីស្នាក់ការសាខា | : លេខ ៦៩ DoH ផ្លូវលេខ ៩៧ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ |
| ៤- | កម្មវត្ថុអាជីវកម្ម | : -ផលិត និងផ្គត់ផ្គង់ទឹកស្អាត <br> -សេវាពិគ្រោះយោបល់លើការងារបណ្តុះបណ្តាល និងអប់រំផ្នែកអនាម័យ និងផ្គត់ផ្គង់ទឹកស្អាត -នាំចូលសំភារៈឧបករណ៍ផលិតទឹកស្អាត ។ |
| ៥- | សញ្ជាតិក្រុមហ៊ុន | : សឹង្ហបុរី |

រាល់ដំណាច់ឆ្នាំនីមួយៗ នាយកសាខាក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់សាខាក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់សាខាពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃសាខាក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**អនុរដ្ឋលេខាធិការ**

**ហូ-សារ៉ាន់**

**<u>ចម្លងជូន:</u>**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល -ក្រសួងសុខាភិបាល
- អគ្គនាយកដ្ឋានរាជកិច្ច និង សៅរ៉ាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៥៤ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១០

# ឆេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ស្មាត អេឡិកទ្រិខល ប្រូដាក់សិន**

**(អេសអ៊ីភី)**

**SMART ELECTRICAL PRODUCTION Co., Ltd.**

**(SEP)**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៤៤០៣/០៩ P ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០៩

មានទម្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ញ៉ាន ឈាងផេង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៥៤ ផ្លូវលេខ ៥៦៦ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -សេវាកម្មផ្នែកអគ្គិសនី : ផ្គត់ផ្គង់ថាមពលអគ្គិសនី តម្លើង និងជួសជុលបណ្តាញអគ្គិសនី សិក្សាគំរោងផ្នែកអគ្គិសនីកម្ម

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-បើកសាលារៀន

-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី

ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុរដ្ឋលេខាធិការ

ហូ-សារ៉ាន់

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ធនាគារជាតិ នៃកម្ពុជា
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងព័ត៌មាន
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

កសន - ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០០៥៥ ពណ.ចបព

ភ្នំពេញថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ធីញ ផាត (ខេមបូឌា) អ៊ិនវេសមេន អ៊ីមផត អិចផត យ៉ូញ ស្តុក ខមភេនី**

**THINH PHAT (CAMBODIA) INVESTMENT IMPORT EXPORT JOINT STOCK COMPANY Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៤៣៦៨/០៩ P ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក VO TAN THINH ប្រធានក្រុមប្រឹក្សាភិបាល
លោក **ហេង ជីន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.០០០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១ A មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ័រណ អាហ័រណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**ហ៊ូ-សារ៉ាន់**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "
- ឯកសារ -កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
**លេខ** ០០៥៦ **ពណ.ចបព**

ភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **វ៉ាយដ៍ អេនធើប្រាយ សឺវីស**

**WIDE ENTERPRISE SERVICE Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៤៣៨១/០៩ P ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក **ទ្រាំ សំណាញ**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ៧ D ផ្លូវលេខ ២១៧ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ និងសំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម -ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះនិងព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ និងពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

៦- ថេរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុន នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**អនុរដ្ឋលេខាធិការ**

**ហ៊ូ-សារ៉ាន់**

**<u>ចម្លងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ " មុខការ "

ស.ន - ឯកសារ -កាលប្បវត្តិ